ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ:.................................

**សូមគោរពជូន**
**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

**តាមរយៈ៖** លោកជំទាវឧត្តមសេនីយ៍ឯក **វេជ្ជ. ប៉ុណ្ណ សំខាន់** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ

**កម្មវត្ថុ៖** សូមគោរពជូនរបាយការណ៍ស្តីពី លទ្ធផលនៃការចូលរួម **កិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពី «ការពង្រឹងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធការប្រឆាំងអំពើជួញដូរមនុស្ស» (Regional Consultation on Enhancing Trafficking in Persons Related Legal Frameworks)** នៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី២០-២១ ខែសីហា ឆ្នាំ២០២៤ ។

**យោង៖** -លិខិតលេខ RSO/24/455 ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤ របស់ អង្គការអន្តរជាតិដើម្បីទេសន្តរប្រវេសន៍ (IOM) និងការិយាល័យគាំទ្រថ្នាក់តំបន់នៃដំណើរការបាលី (RSO of the Bali Process)

-ចំណារឯកភាព លើសំណើសុំគោលការណ៍អនុញ្ញាតចូលរួម **កិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពី «ការពង្រឹងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធការប្រឆាំងអំពើជួញដូរមនុស្ស»** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០២៤ របស់ **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំ សូមគោរពជម្រាបជូន **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ដោយទទួលបានការចាត់តាំង លោកឧត្តមសេនីយ៍ត្រី **តែ សុជាវេត** អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការអនុវត្តច្បាប់ និងនាងខ្ញុំ លោកស្រីវរសេនីយ៍ឯក **ថោង សុវត្ថិ** អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បានចូលរួមជាមួយគណៈប្រតិភូកម្ពុជា៤រូបផ្សេងទៀត ដែលអញ្ជើញមកពី អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងអង្គការ IOM ក្នុង **កិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពី«ការពង្រឹងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធការប្រឆាំងអំពើជួញដូរមនុស្ស» (Regional Consultation on Enhancing Trafficking in Persons Related Legal Frameworks)** កាលពីថ្ងៃទី២០-២១ ខែសីហា ឆ្នាំ២០២៤ នៅសណ្ឋាគារម៉ូវេនភីក (Movenpick BDMS Wellness Resort Bangkok) នាទីក្រុងបាងកក ប្រទេសថៃ ។

## I. ដំណើរការនៃកិច្ចពិគ្រោះយោបល់

ក្នុងនាមរដ្ឋភាគី នៃដំណើរការបាលី (Bali Process) កម្ពុជា ត្រូវបានអញ្ជើញចូលរួម ក្នុងកិច្ចពិគ្រោះយោបល់ ក្នុងគោលបំណង៖

- សម្របសម្រួលកិច្ចពិភាក្សា លើនិយមន័យនៃអំពើជួញដូរមនុស្ស អំពីការយល់ឃើញខុសគ្នា ដើម្បីសម្រួលកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង
- កំណត់នូវការអនុវត្តល្អ កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន និងការរៀបចំក្របខណ្ឌច្បាប់ ដែលអាចចែករំលែកជាមួយដៃគូក្នុងតំបន់
- កំណត់ចំណុចជាអាទិភាព នៃគោលនយោបាយ និងក្របខណ្ឌច្បាប់ប្រឆាំងការជួញដូរមនុស្ស សម្រាប់អនុវត្តក្នុងតំបន់
- បង្កើនការយល់ដឹងអំពីផលប៉ះពាល់ផ្នែកយេនឌ័រនៃបច្ចេកវិទ្យាថ្មី ក្នុងបរិបទនៃអំពើជួញដូរមនុស្ស
- ទទួលស្គាល់របកគំហើញនៃការអង្កេតស្រាវជ្រាវអំពីក្របខណ្ឌច្បាប់នានា ប្រឆាំងអំពើជួញដូរមនុស្ស ក្នុងចំណោមប្រទេសជារដ្ឋភាគីនៃដំណើរការបាលី (Bali Process)

សមាសភាពវាគ្មិន និងអ្នកចូលរួម ជាមន្ត្រីអនុវត្តច្បាប់ មន្ត្រីអន្តោប្រវេសន៍ មន្ត្រីក្រុមការងារចំពោះកិច្ចឬជំនាញ ដែលធ្វើកិច្ចការងារគាំទ្រ និងផ្តល់ជំនួយដល់ជនរងគ្រោះ ព្រមទាំងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អញ្ជើញមកពី ១២ប្រទេស គឺ ប្រទេសអូស្ត្រាលី កម្ពុជា ឥណ្ឌូណេស៊ី ឡាវ នេប៉ាល់ ម៉ាឡេស៊ី ម៉ាល់ឌីវ ហ្វីលីពីន ស្រីលង្កា ថៃ ទីម័រ និងវៀតណាម ។

កិច្ចប្រជុំចាប់ផ្តើម ដោយតំណាង អង្គការអន្តរជាតិដើម្បីទេសន្តរប្រវេសន៍ (IOM) និងការិយាល័យគាំទ្រថ្នាក់តំបន់នៃដំណើរការបាលី (RSO of the Bali Process) ក្នុងនាមជាអ្នកសហការរៀបចំ មានមតិចាប់អារម្មណ៍ អំពីសារសំខាន់ នៃការសិក្សា ស្វែងយល់ ពិភាក្សា ផ្តល់យោបល់ បន្ថែម អំពីក្របខណ្ឌច្បាប់ និងគោលនយោបាយបាយ ឆ្លើយតបនឹងអំពើជួញដូរមនុស្ស ជាពិសេសចំពោះ និន្នាការថ្មីៗនៃបទល្មើសទើបនឹងឃើញកើតមានឡើងច្រើន ដែលតម្រូវឱ្យមានការពិនិត្យលទ្ធភាពកែលម្អ សម្រាប់ប្រើប្រាស់ក្នុងក្របខណ្ឌប្រទេសក្នុងតំបន់ និងទាមទារនូវកិច្ចសហការយ៉ាងមុតមាំ ។

កិច្ចពិគ្រោះយោបល់បានបង្ហាញ តាមរយៈការធ្វើអង្កេត សិក្សាស្រាវជ្រាវ អំពី ស្ថានភាពនៃអំពើជួញដូរមនុស្សក្នុងបរិបទ និងស្ថានភាពក្នុងតំបន់អាស៊ី និងអាស៊ីអាគ្នេយ៍ នាពេលបច្ចុប្បន្ន ។ ក្នុងនោះ តំណាងប្រទេសទាំង១១ នៅតំបន់អាស៊ី រួមមាន កម្ពុជា ឥណ្ឌូណេស៊ី ឡាវ នេប៉ាល់ ម៉ាឡេស៊ី ម៉ាល់ឌីវ ហ្វីលីពីន ស្រីលង្កា ថៃ ទីម័រ និងវៀតណាម បានធ្វើបទបង្ហាញ អំពី ក្របខណ្ឌច្បាប់ និងគោលនយោបាយបាយ ឆ្លើយតបនឹងអំពើជួញដូរមនុស្ស ។

ក្រៅពីនេះ កិច្ចពិគ្រោះយោបល់ បានបើកឱ្យមានការពិភាក្សា តាមរយៈការពិនិត្យមើលករណីសិក្សា ការឆ្លុះបញ្ចាំងបទបង្ហាញតំណាងប្រទេស អំពីស្ថានភាព ភាពគ្រប់គ្រាន់នៃនិយមន័យ «អំពើជួញដូរមនុស្ស» ភាពខុសប្លែកគ្នារវាងអំពើជួញដូរពលកម្ម និងវិវាទការងារ ដើម្បីរួមគ្នាផ្តល់យោបល់ លើភាពចាំបាច់ នៃការកសាងថ្មី ឬ កែសម្រួលច្បាប់និងគោលនយោបាយពាក់ព័ន្ធដែលមានស្រាប់ ។ កិច្ចពិភាក្សា ក៏បានផ្តោតការយកចិត្តទុកដាក់លើទិន្នន័យពាក់ព័ន្ធការជួញដូរមនុស្ស៖ សារសំខាន់នៃការប្រមូល ចងក្រង ចែករំលែក និងប្រើប្រាស់ ។ ក្នុងនោះដែរ ប្រទេសនីមួយៗ បានចូលរួមចែករំលែកនូវ ការអនុវត្តកន្លងមក លទ្ធផល និងភាពប្រឈម ក្នុងការប្រមូល ចងក្រង ចែករំលែក និងប្រើប្រាស់ទិន្នន័យ របស់ខ្លួន ។ អង្គប្រជុំ បានចាប់អារម្មណ៍ លើការចែករំលែកទិន្នន័យ ជាសាធារណៈ ដែលអាចជះផលប៉ះពាល់មួយចំនួនទាក់ទងនឹងឯកជនភាព និងដំណើរការនៃការស៊ើបអង្កេតរឿងក្តី ដែលមិនទាន់បានបញ្ចប់ជាស្ថាពរ ។

នៅចុងបញ្ចប់ នៃកិច្ចពិគ្រោះយោបល់ អ្នកស្រាវជ្រាវ បានបង្ហាញពីការរកឃើញនៃការស្រាវជ្រាវមួយ ក្នុងចំណោមប្រទេស ៤ ក្នុងតំបន់អាស៊ីអាគ្នេយ៍ រួមមាន ប្រទេសកម្ពុជា ឡាវ ម៉ាឡេស៊ី និងឥណ្ឌូណេស៊ី ។ ក្នុងចំណោម សុចនាករទាំងអស់នៃការស្រាវជ្រាវ គណៈប្រតិភូកម្ពុជា បានចាប់អារម្មណ៍ និងចែករំលែកកត្តាប្រឈម អំពី ការចែករំលែកនូវទិន្នន័យនៃភាពរងគ្រោះដោយអំពើជួញដូរមនុស្សដែលចាំបាច់ត្រូវការនូវភាពប្រាកដប្រជា និងជាក់លាក់បន្ទាប់ពីមានការសម្រេចទោសជាស្ថាពរពីស្ថាប័នតុលាការ ក្នុងន័យរក្សាបាននូវការការពារសិទ្ធិបុគ្គល និងគុណភាព ប្រសិទ្ធភាពនៃដំណើរការស៊ើបអង្កេតរឿងក្តី ។

II. **ជាលទ្ធផលៈ**

គណៈប្រតិភូកម្ពុជា ក៏ដូចជា ពីប្រទេស ១១ទៀត រួមមាន ប្រទេសអូស្ត្រាលី ឥណ្ឌូណេស៊ី ឡាវ នេប៉ាល់ ម៉ាឡេស៊ី ម៉ាល់ឌីវ ហ្វីលីពីន ស្រីលង្កា ថៃ ទីម័រ និងវៀតណាម បានបង្ហាញនូវការបន្តឯកភាពគ្នាលើនិយមន័យនៃអំពើជួញដូរមនុស្សដែលបានអនុវត្តតាមពិធីសារប៉ាឡឺម៉ូកន្លងមក ថានៅតែមានវិសាលភាព និងអត្ថន័យគ្រប់គ្រាន់ជាជំនួយដល់ការយល់ឃើញដូចគ្នា និងសម្រួលដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ ហើយបាន បន្តប្តេជ្ញាចិត្តខិតខំប្រឹងប្រែង ក្នុងនាមប្រទេសជាសមាជិក និងក្នុងតំបន់ ជាពិសេសលើការចែករំលែកព័ត៌មានជាក់លាក់ ផ្លូវការ រក្សាបាននូវឯកជនភាព ស្វែងយល់អំពីបទល្មើសក្នុងរូបភាពថ្មីៗ ផ្លាស់ប្តូរយោបល់ និងរិះរកដំណោះស្រាយ បន្តពង្រឹងយន្តការ កសាង និងបច្ចុប្បន្នភាពបទដ្ឋានគតិយុត្តឱ្យសមស្រប ក្នុងកិច្ចសហការកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ដើម្បីឆ្លើយតបនឹងអំពើជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព ។

III. **សេចក្តីសន្និដ្ឋានៈ**

ការចូលរួមក្នុង**កិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពី«ការពង្រឹងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធការប្រឆាំងអំពើជួញដូរមនុស្ស»** របស់គណៈប្រតិភូកម្ពុជានេះបានទទួលជោគជ័យ ដោយបានរួមចំណែក ក្នុងការចែករំលែកបទពិសោធន៍ក្នុងការអនុវត្តច្បាប់ គោលនយោបាយ ជាកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការបើកទូលាយសម្រាប់ការចូលរួមក្នុងភាពជាដៃគូពីបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ ក៏ដូចជា ពីដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចសហការ សហប្រតិបត្តិការ ក្នុងការការពារ និងលើកកម្ពស់ សិទ្ធិ ផលប្រយោជន៍របស់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាបជារបាយការណ៍ ដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃចន្ទ ៧រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤
**អ្នកធ្វើរបាយការណ៍**

បានឃើញ និងសូមគោរពជូន
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃអង្គារ ៨រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤
**អគ្គលេខាធិការ គ.ជ.ប.ជ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ សំខាន់

បានឃើញ
28/08/24